គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ០៤៨ ល.ស /គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧

**សូមគោរពជូន**

**ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រី ក្រសួងបរិស្ថាន**
**និងជាប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព**

**<u>កម្មវត្ថុ</u>**÷ ការចាត់តាំងមន្ត្រី ០១រូប ចូលជាសមាជិកក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុ

**<u>យោង</u>** ÷ លិខិតលេខ ០០៩ ស.ណ ក.ជ.អ.ច របស់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៦

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ សូមជម្រាបជូន **ឯកឧត្តម** មេត្តាជ្រាបថា លេខាធិការដ្ឋាន គ.ជ.អ.ប.បានឯកភាព និងចាត់តាំង **លោក ឈុន ប៊ុនណារ៉ា** ដែលមានតួនាទីជាអនុប្រធានអង្គភាពគ្រប់គ្រង និងគាំទ្រកម្មវិធីនៃលេខាធិការដ្ឋាន គ.ជ.អ.ប. ចូលជាសមាជិកក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុក្នុងគោលបំណងផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់សមាជិក ក.ជ.អ.ច. និងការអនុវត្តសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម** មេត្តាពិនិត្យ និងបញ្ចូលមន្ត្រីនៃលេខាធិការដ្ឋាន គ.ជ.អ.ប ជាសមាជិកក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តម** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

**ជ. ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**